**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងឧស្សាហកម្មនិងសិប្បកម្ម**
**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
លេខ:...០០៩.......ស.ស.រ

# សេចក្ដីសម្រេច
## ស្ដីពីការប្រគល់ភារកិច្ចបន្ថែម

## អគ្គនាយក រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

- បានឃើញព្រះរាជក្រមលេខជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧-០៦-១៩៩៦ ស្ដីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៩១អនក្រ.បក ចុះថ្ងៃទី០៦-០៨-១៩៩៧ ស្ដីពីការអនុវត្តព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ និងអនុក្រឹត្យលេខ៧១អនក្រ.បក ចុះថ្ងៃទី២៦-០៤-២០១១ ស្ដីពីការបំពេញបន្ថែមអនុក្រឹត្យលេខ៩១អនក្រ.បក
- បានឃើញអនុក្រឹត្យលេខ៥២អនក្រ.បក ចុះថ្ងៃទី១៩-១២-១៩៩៦ ស្ដីពីការបង្កើតរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដែលត្រូវបានធ្វើវិសោធនកម្មដោយអនុក្រឹត្យលេខ៣៨អនក្រ.បក ចុះថ្ងៃទី១២-០៦-២០០០ និងអនុក្រឹត្យលេខ១៥អនក្រ.បក ចុះថ្ងៃទី១៩-០៥-២០០៤
- បានឃើញអនុក្រឹត្យលេខ៦៦៤អនក្រ.តត ចុះថ្ងៃទី០៨-០៦-២០១២ ស្ដីពីការតែងតាំងអគ្គនាយក រ.ទ.ស.ភ
- បានឃើញអនុក្រឹត្យលេខ៨៩៩អនក្រ.តត ចុះថ្ងៃទី២៧-០៧-២០១២ ស្ដីពីការតែងតាំងក្រុមប្រឹក្សាភិបាលអាណត្តិទី៥
- បានឃើញអនុក្រឹត្យលេខ៧៦អនក្រ.តត ចុះថ្ងៃទី២៤-០១-២០១៤ ស្ដីពីការតែងតាំងអគ្គនាយករដ្ឋាករទឹកស្វយ័តសៀមរាប អាណត្តិទី៣
- យោងសេចក្ដីសម្រេចលេខ០០២ស.ស.រ ចុះថ្ងៃទី០៣-០១-២០១៣ ស្ដីពីការបែងចែកភារកិច្ចថ្នាក់ដឹកនាំ រ.ទ.ស.ភ ។

## សម្រេច

**ប្រការ ១** : ប្រគល់ភារកិច្ចជូនលោកបណ្ឌិត ជា វិសុទ្ធ បច្ចុប្បន្នជាអគ្គនាយករងទទួលបន្ទុកលេខាធិការសហគ្រាស ឱ្យទទួលខុសត្រូវបន្ថែមលើកិច្ចការរដ្ឋបាលនិងធនធានមនុស្ស ជំនួសលោក យុត វុត្ថារិទ្ធ ដែលត្រូវទៅបំពេញមុខងារជាអគ្គនាយករដ្ឋាករទឹកស្វយ័តសៀមរាប។

**ប្រការ ២** : រាល់សេចក្ដីសម្រេចពីមុនដែលមានខ្លឹមសារផ្ទុយពីសេចក្ដីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៣** : គ្រប់អគ្គនាយករង ប្រធាននាយកដ្ឋាន ការិយាល័យ អង្គភាពចំណុះ រ.ទ.ស.ភ ព្រមទាំងសាមីខ្លួន ត្រូវទទួលអនុវត្តសេចក្ដីសម្រេចនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

*រាជធានីភ្នំពេញ* ថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៤
**អគ្គនាយក**

**ស៊ឹម ស៊ីថា**

<u>កន្លែងទទួល</u> :
- ក្រសួងឧស្សាហកម្មនិងសិប្បកម្ម
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល "*មេត្តាជ្រាប*"
- ដូចក្នុងប្រការ៣ "*ដើម្បីអនុវត្ត-មុខការ*"
- ឯកសារ-កាលប្បវត្តិ